**Alert.seattle.gov/tsunami** (ការជូនដំណឹង.seattle.រដ្ឋាភិបាល/រលកយក្សស៊ូណាមិ)

**ការណ៍ពិត ៖** សេចក្តីប្រកាសឱ្យត្រៀមលក្ខណៈ ចំពោះរលកយក្សស៊ូណាមិ (tsunami) បានចេញផ្សព្វផ្សាយ សម្រាប់ឆ្នេរប៉ាស៊ីហ្វិក នៃរដ្ឋវ៉ាស៊ីនតោន ។ រលកយក្សស៊ូណាមិ គឺជាស៊េរីរលកសមុទ្រ ដែលជាទូទៅបំផុត បង្កឡើងដោយរញ្ជួយផែនដី នៅខាងក្រោមបាតសមុទ្រ ។ រលកសមុទ្រ ក្នុងគ្រប់ទំហំ អាចបង្កើតជាចរន្តទឹកខ្លាំងក្លា ដែលអាចបង្កការខូចខាត និងបោកបក់ទាញយកមនុស្ស បានដោយងាយ ។

**អ្វីដែលត្រូវធ្វើ ៖**

- ប្រសិនបើលោកអ្នកនៅតាមបណ្តោយតំបន់ទល់មុខសមុទ្រ ហើយមានអារម្មណ៍ថា មានរញ្ជួយផែនដី ដំបូង ត្រូវការពារខ្លួនលោកអ្នក ដោយចូលទៅក្រោមតុ ឬគ្រឿងសង្ហារឹម ដែលរឹងមាំ ។ ការរញ្ជួយដី គឺជាសញ្ញាប្រាប់ពីរលកយក្សស៊ូណាមិ ។
  នៅពេលការរញ្ជួយដីឈប់ ត្រូវរត់ទៅ តំបន់ខ្ពស់ ។ ប្រសិនបើគ្មានតំបន់ខ្ពស់ទេ ឬគ្មានពេល ទៅឱ្យដល់តំបន់ខ្ពស់ទេ ឡើងទៅជាន់
  ខ្ពស់ៗ នៃអាគារមានច្រើនជាន់ ។
- ប្រសិនបើមានការប្រាប់ឱ្យជម្លៀសចេញ សូមធ្វើតាមភ្លាម ។ ទៅតាមផ្លូវដែលបាន ណែនាំប្រាប់ ដូចមានផ្តល់ជូននៅក្នុងសេចក្តីជូនដំណឹងអំពីការជម្លៀសចេញ ។ ផ្លូវមួយចំនួន អាចមានផ្លាកសញ្ញា ដាក់នៅតាមបណ្តោយផ្លូវ និងវិថីធំៗ ។
- ប្រសិនបើលោកអ្នកមិនអាចជម្លៀសចេញ តាមយានជំនិះ ត្រូវចាកចេញដោយថ្មើរជើង ហើយ សំដៅឆ្ពោះទៅតំបន់ខ្ពស់ដែលនៅជិតបំផុត ។ ជៀសវាងតំបន់បឹង និងដីសើម ដែលវាងាយរង ការជន់លិច និងការប្រែក្លាយទៅជាទឹក ក្នុងកំឡុងពេលក្រោយកើតហេតុ (aftershocks) ។
- ស្តាប់វិទ្យុ ដើម្បីទទួលបានបច្ចុប្បន្នភាព ពីព័ត៌មានស្តីពីគ្រោះអាសន្ន ។
- *ប្រសិនបើលោកអ្នកស្គាល់បុគ្គលដែលមិនអាច យល់ មើលឃើញ ឬដឹងឮ អំពីសារនេះបានទេសូមជួយប្រាប់ពួកគេផង ។*

តំណរបណ្តាញដែលមានប្រយោជន៍ ៖

http://mil.wa.gov/emergency-management-division/hazards/tsunami

http://www.tsunamiready.noaa.gov/

http://www.ready.gov/tsunamis